ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨៤

ចុះថ្ងៃទី១៧.១២.២០០៣

សាលដីកា

លេខ: ៣២

ចុះថ្ងៃទី៣០.០៦.២០០៤

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសម្ងាត់ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឃឹម ស៊ីផល ចៅក្រម

៣ - លោក ព្រាក់ គីមសាន ចៅក្រម

៤ - លោក ជ័ប៉ិន សារឿន ចៅក្រម

៥ - លោក យស់ សុខឿន ចៅក្រមរាយការណ៍

លោក យ៉ាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី០៩.០៧.២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៨៤ ចុះថ្ងៃទី១៧.១២.២០០៣ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ មឿង វុទ្ធី "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ៣៩ ឆ្នាំ ជាតិ ខ្មែរ មានទីលំនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ សព្វថ្ងៃនៅពន្ធនាគារព្រៃសរ ។

- ត្រូវចោទពីបទៈ រំលោភសេពសន្ថវៈនិងប្រើប្រាស់អាវុធខុសច្បាប់ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទីខែ០១ ឆ្នាំ ១៩៩៩ ។

- មេធាវី លោក កៅ ទី

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លឹម រតនា "ចុងបណ្តឹងសាទុក្ខ" ភេទ ស្រី ទីលំនៅសព្វថ្ងៃ តុលាការយោធា សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ មានកូនឈ្មោះសុវត្ថិ កិត្យា ភេទ ស្រី អាយុ ១៤ ឆ្នាំ ។

- មេធាវី គ្មាន

- តាមពាក្យបណ្តឹងរបស់ឈ្មោះលឹម រតនា ចុះថ្ងៃទី២១.៣.១៩៩៩ ប្តឹងពីឈ្មោះ មឿង វុទ្ធី ដែលបានចាប់រំលោភសេពសន្ថវៈកូនខ្លួន ឈ្មោះ សុវត្ថិ កិត្យា ។

144

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញសំរេច ៖ ចោទប្រកាន់លើឈ្មោះ មឿង វុទ្ធី ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែ០១ ឆ្នាំ១៩៩៩ តាមមាត្រា៣៣និង៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥៤ "ព" ចុះថ្ងៃទី០២ ១២ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានសេចក្តីសំរេចដូចតទៅ ៖

១ - ផ្តន្ទាទោសឈ្មោះ មឿង វុទ្ធី ភេទប្រុស អាយុ៣៩ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១០ ឆ្នាំ "ជាប់ឆ្នាំ" គិតពីថ្ងៃឃុំខ្លួន២៣ - ៧ - ១៩៩៩ ពីបទរំលោភសេពសន្ថវៈនិងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែមករា ឆ្នាំ១៩៩៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៣៣និង៥៤នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ។

២ - បង្គាប់អោយឈ្មោះមឿង វុទ្ធី សងជំងឺចិត្តនៃការខូចខាតកិត្តិយសចំនួន៣.០០០ ដុល្លាអាមេរិក អោយទៅឈ្មោះលឹម វតនា ជាដើមបណ្តឹងរដ្ឋប្បវេណី ។ សំណូមពរលើសពីនេះសំរេចបដិសេធចោល ។

- ក្នុងករណីទណ្ឌិតខាងលើ មិនយកប្រាក់មកសងសំរេច ដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ.

៣.រិបអាវុធមានអាវុធខ្លីគុនកា ៥៩ មួយដើមលេខ១៣៩៩៤ សំរេចរឹបអូសទុកជាសម្បត្តិរដ្ឋ.

- នាឡិកាដៃមួយគ្រឿងម៉ាកមីដូ ពណ៌លឿងលេខ១៣៥៧៣ និងវ៉ែនតាមួយម៉ាក រ៉េបាន់ ពណ៌ទឹកតែ សំរេចប្រគល់អោយឈ្មោះមឿង វុទ្ធី ប្រើប្រាស់វិញ ។

៤ - សាលក្រមនេះជំនុំជំរះដាសម្នាក់ តែប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ចំពោះមុខជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារអោយជនជាប់ចោទ និង មេធាវីការពារអោយជនរងគ្រោះ សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៣៥ "ព" ចុះថ្ងៃទី០៨ ១២ ១៩៩៩ របស់លោក ពុធ ធារី មេធាវីការពារឱ្យជនជាប់ចោទ តវ៉ាមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៥៤ចុះថ្ងៃទី០២ ១២ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បាន ឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍សំរេច ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨ ១២ ១៩៩៩ របស់លោកមេធាវី ពុធ ធារី ការពារឱ្យជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្លូវនីងគតិច្បាប់ ។

២ - តំកល់សាលក្រមព្រហ្មទណ្ឌលេខ ៥៤ "ព" ចុះថ្ងៃទី០២ ១២ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី០៥ ០៧ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានសេចក្តីសំរេចដូចតទៅ ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨ ១២ ១៩៩៩ របស់មេធាវីការពារឱ្យជនជាប់ចោទ ឈ្មោះ មឿង វុទ្ធី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាល់នឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៤ "ពញ" ចុះថ្ងៃទី០២ ១២ ១៩៩៩ របស់តុលាការ ក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទនិង មេធាវីជនជាប់ចោទនិងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី១៨ ០៧ ២០០៣ របស់ឈ្មោះ មឿង វុទ្ធី តវ៉ា មិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ដ" ចុះថ្ងៃទី០៩ ០៧ ២០០៣ របស់ សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី០៨ ០១ ២០០៤ របស់លោកកៅ ទី មេធាវីការពារឱ្យឈ្មោះ មឿង វុទ្ធី .

- បានឃើញសារណាតបចុះថ្ងៃទី១៥ ០៣ ២០០៤ របស់ឈ្មោះ លឹម រតនា .

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: រឿងនេះជនជាប់ចោទបានទទួលស្គាល់និងសារភាព នៅចំពោះមុខតុលាការថ្នាក់ក្រោមអស់ហើយ សាលាឧទ្ធរណ៍ក៏បានសំរេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យនិងសំរេច ។

- បានស្ដាប់សាវតាជាតិឈ្មោះ មឿង វុទ្ធី និងចម្លើយអះអាងនាពេលសវនាការថា: ខ្ញុំបានប្រព្រឹត្តពិតមែន តែកើតឡើងដោយសារការព្រមព្រៀងគ្នាប៉ុណ្ណោះ ម្យ៉ាងវិញទៀតខ្ញុំបានកំចាយទាំងផ្ទះ ទាំងប្រាក់លើគ្រួសារនោះច្រើនដែរ ។ ពេលនេះខ្ញុំមានជម្ងឺផង សុំព្រះរាជ្យឈរនៅក្រៅឃុំបណ្ដោះអាសន្នសិន នឹងសុំបន្ធូរបន្ថយទោស តាមការអនុគ្រោះពីក្រុមប្រឹក្សាជំនុំជំរះ ។

- បានស្ដាប់សាវតាជាតិឈ្មោះលឹម រតនា ជាដើមបណ្ដឹងរដ្ឋប្បវេណីនិងត្រូវជាម្ដាយជនរងគ្រោះ ព្រមទាំងចម្លើយអះអាងនាពេលសវនាការថា:ការកើតរឿងទាំងអស់នោះនាងខ្ញុំរវល់ធ្វើការឆ្ងាយៗ មានតែមឿង វុទ្ធី ជាប្ដីដែលនៅផ្ទះ ហើយលួចលោមចាប់រំលោភកូនខ្លួនឯងនោះ ទើបនាងខ្ញុំប្ដឹងពីការប្រព្រឹត្តរបស់គាត់ ។សូមអង្គសវនាការមេត្តាវិនិច្ឆ័យសេចក្ដីតាមច្បាប់ ។

- បានស្ដាប់មេធាវីលោក កៅទី ការពារឱ្យជនជាប់ចោទ បានឡើងសន្និដ្ឋាននាពេលសវនាការថា: ចំពោះរឿងរំលោភសេពសន្ថវៈនេះ គឺមិនត្រឹមត្រូវតាមការចោទប្រកាន់របស់តុលាការក្រុងនិងសាលាឧទ្ធរណ៍ឡើយ ពីព្រោះថា:កូនក្ដីខ្ញុំមិនមែនរួមរក័ក្ខាតែម្នងទេ គឺច្រើនដង បើតាមចំលើយរបស់នារីនោះនៅក្នុងកំណត់ហេតុវិញ មានរាប់ឆ្នាំមកហើយ ។ ប៉ុន្តែម្ដាយជាអ្នកប្ដឹងឱ្យធ្វើការចោទប្រកាន់នឹងចាប់ឃុំខ្លួន ពុំបានពិចារណាល្អិតល្អន់ធ្វើការដែកនេះចាប់បង្ខំរូបកាយទាំងស្រុង ។ សមត្ថកិច្ចតុលាការក៏ធ្វើការស៊ើបអង្កេតគ្មានសាក្សីនិងភស្តុតាងច្បាស់លាស់អាចគម្លាតចេញពីច្បាប់ រដ្ឋធម្មនុញ្ញ និង ព្រហ្មទណ្ឌអន្តរកាល ។

សូមក្រុមប្រឹក្សាក្នុងសវនាការថ្ងៃនេះមេត្តាសំរេចដោះលែងកូនក្ដីខ្ញុំអោយមានសេរីភាពឡើងវិញផង និងសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា: សូមរក្សាការសន្និដ្ឋាន

របស់ខ្លួន ទុកជាបានការដដែល ពុំមានអ្វីបន្ថែមទៀតទេ ។

- ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ របស់ដើមបណ្តឹង រដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានការពារ មេធាវី របស់ជនជាប់ចោទ ។

- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៣ របស់ ឈ្មោះ ម៉េង វុទ្ធី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាច លើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់មេធាវី ជនជាប់ចោទ ក្នុងសារណា ចុះថ្ងៃទី ០៨-០១-២០០៤ ថា សាលាឧទ្ធរណ៍ ពុំបានសំរេចអោយកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ដោយកូនក្តីខ្លួន ពុំបានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ និង ប្រើប្រាស់អាវុធខុសច្បាប់នោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

។ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ ម៉េង វុទ្ធី ពិតជាបានរំលោភសេពសន្ថវៈលើនារី សុវត្ថិ កិត្យា ជាច្រើនលើកមែន ដោយជនជាប់ចោទបានឆ្លើយសារភាព នៅចំពោះមុខ អយ្យការ ក៏ដូចចៅក្រមស៊ើបអង្កេត ។ ជនជាប់ចោទត្រូវជាឪពុកចុង មានឥទ្ធិពល ទៅលើជនរងគ្រោះ និង មានការគំរាមកំហែងផង ។

។ វិញ្ញាបនប័ត្រពេទ្យលេខ ២៣២ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៩ របស់មន្ទីរពេទ្យ ព្រះបាទនរោត្តម សីហនុ បានបញ្ជាក់ថា មានសំណករហែកសន្ធះព្រហ្មចារីយ៍ ដោយការរំលោភផ្លូវភេទ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ថា ជនជាប់ចោទបានប្រើប្រាស់អាវុធខុសច្បាប់ ដោយបានរក្សាទុក កាំភ្លើងខ្លីមួយដើមម៉ាកកា-៥៩ លេខ ៣៩៨៤ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៣ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខ ជនជាប់ចោទ និង
ដើមបណ្តឹងរដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៣ របស់ ឈ្មោះ មឿង ឌុទ្ធី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស នឹង គតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៣ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះជាសម្ងាត់ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤ ។